ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករគណនេយ្យនិងសវនកម្ម

លេខ ០៦១១/២៤.......ន. គ. ស/សរ.ណ.

## សេចក្តីជូនដំណឹង

## ស្តីពី

## ការចូលជាធរមាននៃ ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ លេខ ១៨ "ការដាក់បង្ហាញ និងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ" ចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ

និយ័តករគណនេយ្យនិងសវនកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រប់ម្ចាស់សហគ្រាស ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ សវនករ និងសាធារណជនទូទៅ ឱ្យបានជ្រាបថា÷ នាថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២៤ ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standards Board) ដែលជាស្ថាប័នឯករាជ្យក្នុងការអភិវឌ្ឍ និងអនុម័តលើស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ បានចេញផ្សាយនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ លេខ ១៨ "ការដាក់បង្ហាញ និងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ" ដែលនឹងជំនួសស្តង់ដាគណនេយ្យអន្តរជាតិ លេខ ១ "ការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ"។

ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ លេខ ១៨ "ការដាក់បង្ហាញ និងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ" នឹងចូលជាធរមានចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៧ តទៅ ជាមួយនឹងការលើកទឹកចិត្តឱ្យអនុវត្តមុនកាលបរិច្ឆេទកំណត់នេះបាន។

សម្រាប់ព័ត៌មានលម្អិត សូមចូលទៅកាន់គេហទំព័ររបស់និយ័តករ : www.acar.gov.kh។

អាស្រ័យហេតុនេះ សូមម្ចាស់សហគ្រាស ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ និងសវនករ ជ្រាបជាព័ត៌មាន និងត្រូវត្រៀមលក្ខណៈឱ្យបានរួចរាល់សម្រាប់ការអនុវត្តស្តង់ដាថ្មីនេះនៅកម្ពុជាទៅតាមពេលវេលាកំណត់ខាងលើ។

ថ្ងៃព្រហស្បតិ៍ ២ រោច ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០២៤

អគ្គនាយក

ប៊ូ ផារិន

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីមែល : info@acar.gov.kh
ទូរស័ព្ទ ០២៣ ៨៨២ ១១១
Phone: 023 882 111